# វ្រីហិគ្ហហនៅបរិវេណប្រាសាទព្រះខ័ន

ប្រាសាទព្រះខ័ន មានទីតាំងស្ថិតនៅក្នុងតំបន់អង្គរ (វង់ធំ) ខេត្តសៀមរាប ចម្ងាយប្រមាណ ២,៥ គីឡូម៉ែត្រ ប៉ែកឦសានប្រាសាទបាយ័ន។ នៅក្នុងមជ្ឈដ្ឋានអ្នកស្រាវជ្រាវ គេស្គាល់ជាទូទៅថា ប្រាសាទព្រះខ័ន មានឈ្មោះដើមថា "**ជយស្រី**" កសាងឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដើម្បីឧទ្ទិសដល់ព្រះវរបិតារបស់ព្រះអង្គ គឺព្រះបាទធរណីន្ទ្រវរ្ម័នទី២ ក្នុងទម្រង់ជាព្រះពោធិសត្វ អវលោកិតេស្វរ ក្រោមព្រះនាមថា "**ជយវរ្មេស្វរ**"។ គួរឱ្យចាប់អារម្មណ៍ នៅក្នុងបរិវេណកំពែងទី៣ (ប៉ែកឦសាន) មានអគាររាងបួនជ្រុងទ្រវែងមួយធ្វើអំពីថ្មភក់ដែលមានបង្អួច រចនាសម្ព័ន្ធ និងរូបរាង ចម្លែកពីអគារនៅតាមប្រាសាទផ្សេងៗក្នុងប្រទេសកម្ពុជា ដែលបង្កើតជាចម្ងល់ជាច្រើនអំពីតួនាទីរបស់អគារមួយនេះជាច្រើនទសវត្សរ៍។ ប៉ុន្តែ បន្ទាប់ពីមានការរកឃើញថ្មគោលចារឹកនៅប្រាសាទព្រះខ័ន កាលពីឆ្នាំ១៩៣៩ មក ការសន្និដ្ឋានអំពីតួនាទីដើមនៃអគារនេះ ចេះតែមានជាបន្តបន្ទាប់ រហូតមកទល់បច្ចុប្បន្នគេសន្និដ្ឋានថា អគារពីរជាន់ដ៏ចម្លែកនេះជា "វ្រីហិគ្ហហ"។ តើ "វ្រីហិគ្ហហ" គឺជាអ្វី និងមានតួនាទីដូចម្តេចខ្លះ?

ពាក្យ "**វ្រីហិគ្ហហ**" ជាភាសាសំស្ក្រឹតដែលផ្សំឡើងអំពីពាក្យចំនួន ២ ពោល គឺពាក្យ "**វ្រីហិ**" មានន័យថា "ស្រូវ" ឬ "ស្រូវដែលទើបច្រូតថ្មីៗ" និងពាក្យ "**គ្ហហ**" ប្រែថា "ផ្ទះ" ឬ "រោង" ឬ "សាលា" ឬ "ឃ្លាំង"។ ម្ល៉ោះហើយ "វ្រីហិគ្ហហ" មានន័យថា "**ឃ្លាំងឬជង្រុកសម្រាប់ផ្ទុកផលស្រូវដែលទើបប្រមូលផល**" ឬអាចប្រែដោយកាត់ខ្លីថា "ឃ្លាំងស្រូវ", "ជង្រុកស្រូវ", "ផ្ទះស្រូវ", "សាលាស្រូវ"។ ពាក្យ "វ្រីហិគ្ហហ" គេប្រទះឃើញនៅក្នុងគាថាទី៣៩ នៃថ្មគោលសិលាចារឹកព្រះខ័ន ដែលមានខ្លឹមសារទាំងស្រុងថា៖

ឯកោ វ្រីហិ-គ្ហហេ ទេវស　　　ចន្ទ្រិមេសុ បុនរ ទស
ចត្វារស ចឧបកាយ៉ាយាម　　　អារោគ្យ អាយតនេ ត្រយះ

ប្រែថា៖

*"ទេវតាមួយអង្គគង់នៅឃ្លាំងស្រូវ បន្ទាប់មកដប់អង្គគង់នៅតាមថែវ (ថែវប្រទក្សិណា), បួនអង្គគង់នៅសាលាសំណាក់ (ផ្ទះសម្រាកតាមផ្លូវ), និងបីអង្គគង់នៅក្នុងមន្ទីរពេទ្យ"។*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

តាមន័យខាងលើដែលរៀបរាប់ថា សំណង់នេះមានតម្កល់ទេវរូប (ប្រតិមា) តែមួយអង្គគង់នៅទីនោះ នាំឱ្យគេដឹងថា សំណង់នេះជាប្រភេទសំណង់ទោលមានតែមួយគត់។ នៅក្នុងឆ្នាំ១៩៤១ លោក George Coedès ដែលជាអ្នកប្រាជ្ញដំបូងគេបង្អស់ដែលបានបកប្រែសិលាចារឹកព្រះខ័ន បានសន្និដ្ឋានថា "វ្រីហិគ្គួហ" ឬ "ឃ្លាំងស្រូវ" ដែលរៀបរាប់នៅក្នុងគាថាទី៣៩ នេះ គឺប្រហែលជា "សំណង់ថ្មបាយក្រៀមគ្រើមៗដែលស្ថិតនៅក្នុងកំពែងជាន់ទី៣"។ លុះមកដល់ឆ្នាំ១៩៩៣ លោក Christophe Pottier បានសន្និដ្ឋានថា "វ្រីហិគ្គួហ" ឬ "ឃ្លាំងស្រូវ" គឺជាវិហារដែលមានសសររាងមូលដ៏អាថ៌កំបាំងនៃប្រាសាទព្រះខ័ន។ សម្មតិកម្មរបស់លោក Christophe Pottier ត្រូវបានយល់ស្របទាំងស្រុងដោយលោក Thomas Stuart Maxwell នៅក្នុងអត្ថបទស្រាវជ្រាវរបស់លោកក្នុងឆ្នាំ២០០៧។ ក្នុងនោះ លោក Thomas Stuart Maxwell យល់ថា បើទោះបីជាសិលាចារឹកមិនបានផ្ដល់ព័ត៌មានលម្អិតចំៗអំពីទីតាំង ឬអត្តសញ្ញាណរបស់ទេវរូបដែលតម្កល់នៅទីនោះក៏ដោយ លោកជឿថា "វ្រីហិគ្គួហ" ឬ "ឃ្លាំងស្រូវ" គឺពិតជាសំណង់រាងបួនជ្រុងទ្រវែងដែលមានសសររាងមូលដ៏ស្ដឹមស្ដៃ (សំណង់លេខ១៤៦) ស្ថិតនៅប៉ែកឦសាននៃកំពែងជាន់ទីបី ព្រោះស្ថាបត្យកម្មនេះរចនាឡើងដោយផ្ដាច់តួអគារឱ្យផុតពីដី មានសសរមូលៗដែលមិនអាចតោងឡើងបាន មិនមានជណ្ដើរអចិន្ត្រៃយ៍ឡើងទៅជាន់លើ និងមានគិតគូរអំពីប្រព័ន្ធខ្យល់ចេញចូលបានល្អជាងសំណង់ដទៃទៀត។

លោក Thomas Stuart Maxwell គិតថា ទេវរូបចំនួនមួយអង្គដែលតម្កល់នៅ "វ្រីហិគ្គួហ" ឬ "ឃ្លាំងស្រូវ" គឺប្រហែលជា "វ្រះវៃស្រវ" ឬ "ព្រះពៃស្រពណ៍" ដែលគេស្គាល់ថាជាព្រះអាទិទេពតំណាងឱ្យស្រូវ ហើយរូបប្រតិមាធ្វើអំពីថ្មពិតជាមាននៅសម័យអង្គរ។ ប៉ុន្តែ លោកគិតថា ទេវរូបនេះមិនមែនតម្កល់នៅលើអគារវ្រីហិគ្គួហនេះទេ តែគេតម្កល់នៅលើប្រាសាទតូចមួយនៅលើខឿនថ្មបាយក្រៀមវែង (សំណង់លេខ១៤២) ដែលស្ថិតនៅខាងលិច និងស្របអ័ក្សគ្នាជាមួយអគារនេះ។ ប្រាសាទតូចមួយនៅលើខឿនថ្មបាយក្រៀមនេះ បានបាត់បង់រូបរាងអស់ទៅហើយ តែបំណែកថ្មភក់ និងផ្នែកខ្លះនៃជើងទម្រនៅតែអាចមើលឃើញនៅលើខឿនថ្មបាយក្រៀមនេះ។ ក្នុងនោះ បានជាកម្ពស់ខឿនថ្មបាយក្រៀមនេះមានកម្ពស់ស្មើទៅនឹងកម្រិតជាន់ទីមួយនៃអគារ "វ្រីហិគ្គួហ" មកពីគេធ្វើឡើងដើម្បីដាក់តម្កល់ប្រតិមា "ព្រះពៃស្រពណ៍" ឱ្យស្មើទៅនឹងជាន់ទីមួយនៃអគារនោះ ដែលជាន់ទីមួយនោះហើយ គឺជាកន្លែងផ្ទុកស្រូវជានិម្មិតរូប។ ដូច្នេះ រូបប្រតិមាព្រះពៃស្រពណ៍ នឹងត្រូវ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បែរព្រះភក្ត្រសំដៅទៅរកឃ្លាំងស្រូវដែលព្រះអង្គត្រូវតាមថែរក្សាការពារ ដោយសារតែប្រាសាទរបស់ព្រះអង្គស្ថិតនៅទិសខាងលិចនៃឃ្លាំង ហើយព្រះអង្គនឹងបែរទៅទិសខាងកើត។

អ្វីដែលជាចម្ងល់នោះគឺនៅត្រង់ថា តើអគារ "វ្រីហិគ្គហ" ឬ "ឃ្លាំងស្រូវ" នេះ ពិតជាដើរតួនាទីជាជង្រុក ឬឃ្លាំងស្រូវពិតប្រាកដមែន ឬគ្រាន់តែជានិម្មិតរូប ឬគ្រាន់ជាកន្លែងធ្វើកិច្ចពិធីសាសនាពាក់ព័ន្ធជាមួយទ្រព្យហ្លួង? ដោយសារតែអគារនេះសាងសង់ឡើងអំពីថ្ម មានការរចនាយ៉ាងល្អប្រណីត និងមានលក្ខណៈស្ថាបត្យកម្មដ៏ស្កឹមស្កៃ នាំឱ្យលោក Thomas Stuart Maxwell យល់ថា សំណង់វ្រីហិគ្គហនេះត្រូវតែជាឃ្លាំងរាជវាំងចម្បង ពោល គឺស្របទៅតាមគាថាទី៧៨ នៃសិលាចារឹកព្រះខ័ន ដែលរៀបរាប់ថា *"អ្វីដែលត្រូវដកយកជារៀងរាល់ឆ្នាំពីឃ្លាំងរាជវាំង គឺស្រូវ (ឬអង្ករ) ចំនួន ១,៣២៨ ខារី និង ២ ទ្រោណស"*។ ប៉ុន្តែ មុខងារប្រើប្រាស់ជាក់ស្តែងរបស់អគារនេះហាក់ដូចជាលើសកម្រិតបន្តិច ដោយសារតែទំហំផ្ទុកតូច ប្រៀបធៀបទៅនឹងបរិមាណស្បៀងអាហារដែលត្រូវដាក់តម្កល់ក្នុងឃ្លាំង (ដូចមានរៀបរាប់សិលាចារឹកព្រះខ័ន គាថាទី៧៨ដល់៩២)។ ម្ល៉ោះហើយ ទោះបីជាអគារឃ្លាំងស្រូវនេះមើលទៅតូច បើធៀបនឹងបរិមាណស្បៀងទាំងអស់ក្នុងប្រាសាទ ប៉ុន្តែអគារនេះមានតួនាទីជា "មជ្ឈមណ្ឌលចែកចាយស្បៀង" ក្នុងពិធីសាសនា (ផ្គត់ផ្គង់ទៅបរិវេណខាងក្នុងប្រាសាទ) និងជានិម្មិតរូបតំណាងឱ្យព្រះមហាក្សត្រ ព្រោះគេប្រៀបប្រដូចព្រះអង្គទៅនឹង "ប្រភព" និង "ជាអ្នកប្រទានផលដំណាំដល់ប្រជានុរាស្ត្រ"។

សូមបញ្ជាក់ថា នៅមុនឆ្នាំ១៩៣០ ប្រាសាទព្រះខ័នទាំងមូល រួមទាំងអគារ "វ្រីហិគ្គហ" ឬ "ឃ្លាំងស្រូវ" នេះផង ត្រូវបានដុះគ្របដណ្តប់ទៅដោយព្រៃក្រាស់ៗ និងឫសឈើធំៗ។ នៅចុងឆ្នាំ ១៩៣០ ក្រុមអ្នកអភិរក្សសាលាបារាំងចុងបូព៌ាប្រទេស ដឹកនាំដោយលោក Henri Marchal បានចាប់ផ្តើមយុទ្ធនាការឆ្ការព្រៃ ដកឫសឈើ និងកាយដីដែលកប់នៅជើងសសរអគារនេះចេញ។ ការសម្អាតនេះជួយឱ្យគេមើលឃើញទម្រង់ស្ថាបត្យកម្មពីរជាន់ និងជួរជើងសសររាងមូលនៃអគារនេះកាន់តែច្បាស់លាស់ និងអាចវាយតម្លៃពីកម្រិតខូចខាតដើម្បីត្រៀមជួសជុល។ មុននឹងឈានទៅដល់ការរុះរើ និងជួសជុលអគារនេះឡើងវិញ បុរាណវិទូ និងស្ថាបត្យករបារាំង បានចាប់ផ្តើមគូរគំនូរប្លង់នៃអគារនេះឡើងវិញ ដែលដឹកនាំដោយលោក Maurice Glaize នៅឆ្នាំ១៩៣៧។ ការងារជួសជុលតាមបែបអាណាស្ទីឡូស បានចាប់ផ្តើមឡើងនៅដើមទសវត្សរ៍១៩៥០ រហូតបានសម្រេចជោគជ័យទាំងស្រុងនៅឆ្នាំ១៩៥២។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# អត្ថបទ៖ វ្រីហិគ្ឫហនៅបរិវេណប្រាសាទព្រះខ័ន

ជារួមមក អគារពីរជាន់ដ៏ចម្លែកនៅបរិវេណប្រាសាទព្រះខ័ន ដែលអ្នកស្រាវជ្រាវសន្និដ្ឋានថាជា «វ្រីហិគ្ឫហ» ឬ «ឃ្លាំងស្រូវ» នេះ មិនត្រឹមតែដើរតួជាមជ្ឈមណ្ឌលចែកចាយស្បៀងក្នុងពិធីសាសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជានិមិត្តរូបឆ្លុះបញ្ចាំងពីព្រះមហាក្សត្រខ្មែរ ដែលជាប្រភពនៃការប្រទានផលដំណាំដល់ប្រជានុរាស្ត្រ។ ទន្ទឹមនឹងនេះ ទំនាក់ទំនងរវាងឃ្លាំងស្រូវ និងខឿនតម្កល់បដិមា «ព្រះពៃស្រពណ៌» (អាទិទេពថែរក្សាស្រូវ) នៅទិសខាងលិច បានបង្ហាញយ៉ាងច្បាស់ពីការផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតរវាងស្ថាបត្យកម្ម ជំនឿសាសនា និងជីវភាពកសិកម្មសម័យអង្គរ។ សំណង់ដ៏កម្រមួយនេះ គឺជាសក្ខីភាពប្រវត្តិសាស្ត្រដ៏រស់រវើក មិនត្រឹមតែបង្ហាញពីភាពច្នៃប្រតិដ្ឋខ្ពស់ខាងផ្នែកស្ថាបត្យកម្មដែលខុសប្លែកពីប្រាសាទដទៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីភាពរុងរឿងខាងផ្នែកអរិយធម៌ ក៏ដូចជាសមត្ថភាពដ៏វិសេសវិសាលរបស់បុព្វបុរសខ្មែរ ក្នុងការគ្រប់គ្រងស្បៀងអាហារ និងរៀបចំកិច្ចការនគរនាសម័យអាណាចក្រអង្គរផងដែរ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## បញ្ជីឯកសារពិគ្រោះ

Coedès, G., 1941, “La stèle du Práh Khān d’Angkor”, *Bulletin de l'École française d'Extrême-Orient (BEFEO)*. 41:255-302.

Coedès, G., 1951 (1), “L’épigraphie des monuments de Jayavarman VII”, *BEFEO* 44:97-119.

Glaize, M., 1944. *Les Monuments du groupe d'Angkor*. Saïgon: Albert Portail.

Jacques, C. (no date), “La stèle de Preah Khan K 908” [unpublished manuscript; referred to in the text as Jacques MS].

Marchal, H., 1933. Notes sur Práh Khăn. *Bulletin de l'École française d'Extrême-Orient (BEFEO)*, 33(1), pp.517-522.

Marchal, H., 1939. *La reconstruction des monuments d'Angkor par la méthode d'anastylose*. Saïgon: Imprimerie d'Extrême-Orient.

World Monuments Fund, 1992. *Preah Khan Conservation Project: Historic City of Angkor*. New York: World Monuments Fund.

Maxwell, T.S., 2007. The Stele Inscription of Preah Khan, Angkor: Text with Translation and Commentary. *Udaya*: Journal of Khmer Studies, 8, pp. 1-131.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



ង់ វ៉ាលី



រូបលេខ២៖ អគារ "វ្រីហិគ្គូហ" ឬ "ឃ្លាំងស្រូវ" នៅប្រាសាទព្រះខ័ន (ខែធ្នូ ឆ្នាំ១៩៣០)
(ប្រភព៖ EFEO Collection)



ង់ វ៉ាលី



រូបលេខ៤៖ ទិដ្ឋភាពនៃការជួសជុលអគារ "វ្រីហិគ្គូហ" ឬ "ឃ្លាំងស្រូវ" នៅប្រាសាទព្រះខ័ន (ខែកក្កដា ឆ្នាំ១៩៥១) (ប្រភព៖ EFEO Collection)



ម៉ង់ វ៉ាលី



រូបលេខ២៦៖ ទិដ្ឋភាពអគារ "វ្រីហិគ្គហ" ឬ "ឃ្លាំងស្រូវ" នៅប្រាសាទព្រះខ័ន
(ខែមីនា ឆ្នាំ១៩៦២) (ប្រភព៖ EFEO Collection)



វ៉ វ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៨៖ អគារ "វ្រីហិគ្ឫហ" ឬ "ឃ្លាំងស្រូវ" នៅប្រាសាទព្រះខ័ន

(ប្រភព៖ www.flickr.com)



បី

